ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៣៤ អយក.៧៥៧

# សេចក្តីជូនដំណឹង

## ស្តីពីការផ្អាកជាបណ្តោះអាសន្នដំណើរការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកអប់រំ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២១

ដើម្បីពង្រឹងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពព្រមទាំងយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សម្រេចផ្អាកជាបណ្តោះអាសន្នការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកអប់រំ មន្ត្រីជាប់កិច្ចសន្យា នៃអង្គភាពអប់រំ និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ព្រមទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ នៅរាជធានីភ្នំពេញ ដោយគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១។ ក្រសួងនឹងជម្រាបជូនអំពីកាលបរិច្ឆេទ នៃការបន្តដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ នៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី នាងកញ្ញា ជ្រាប និងចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសៅរ៍ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន:**

- រដ្ឋបាលរាជធានីភ្នំពេញ ខេត្តកណ្តាល
- គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
  "ដើម្បីជូនជ្រាប និងសហការ"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh